**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតថ្វាយព្រះរាជកុសល

**ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ***ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងសូមក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីលើកខួប **៩ឆ្នាំ** នៃការយាងសោយព្រះទិវង្គតរបស់ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ១៥ តុលា ឆ្នាំ២០១២ - ១៥ តុលា ឆ្នាំ២០២១។ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតចូលរួមថ្វាយព្រះរាជកុសល និងសូមធ្វើអភិវន្ទនកិច្ចពោរពេញដោយសេចក្តីសោកស្តាយ អាឡោះអាល័យជាអនេកប្បការ ចំពោះការសោយទិវង្គត នៃ**ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមយាងដួងព្រះវិញ្ញាណក្ខន្ធនៃព្រះករុណា **"ព្រះបរមរតនកោដ្ឋ"** សោយព្រះបរមសុខ ក្នុងព្រះសុគតិភពកុំបីអាក់ខានឡើយ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ព្រះមេត្តាប្រោសទទួលនូវគោរវភក្តីភាពដ៏ស្មោះត្រង់ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវិត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh